ក្រសួងមហាផ្ទៃ
លេខ ០០២ សរ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## <u>សារាចរ</u>

## អនុវត្តច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង

ដើម្បីធានាការអនុវត្តន៍ច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង ដែលប្រកាស់អោយប្រើដោយព្រះរាជក្រមលេខ នស/កម/០១៩៦/២៨ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ អោយមានប្រសិទ្ធិភាពក្រសួងសូមណែនាំនូវវិធានការដូចខាងក្រោមនេះ ៖

១-អភិបាលខេត្ត-ក្រុងនិងប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ និងក្រុងកែប ក្នុងតួនាទីជាប្រធានគណៈបញ្ជាការឯកភាពខេត្ត-ក្រុង ត្រូវមានវិធានការម៉ឺងម៉ាត់ដល់មន្ត្រីរាជការស៊ីវិល នគរបាលជាតិ ក៏ដូចជាប្រជាពលរដ្ឋទាំងអស់ដែលស្ថិតនៅក្រោមឱវាទ និងកំពុងរស់នៅក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួនអោយអនុវត្តច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសងដោយហាមមិនអោយមន្ត្រីរាជការស៊ីវិល នគរបាលជាតិ កងយោធពលខេមរៈភូមិន្ទ កងរាជអាវុធហត្ថ និង ប្រជាពលរដ្ឋទាំងអស់លេងល្បែងស៊ីសង ឬការពារ ឬ បើកបនល្បែងស៊ីសងជាដាច់ខាត ។

អ្នកប្រព្រឹត្តបទល្មើស ត្រូវចាប់បញ្ជូនខ្លួនទៅតុលាការ ។

២-អំពីសមត្ថកិច្ចក្នុងការបង្រ្កបល្បែងស៊ីសង ៖

ការបង្រ្កាបល្បែងស៊ីសងជាសមត្ថកិច្ចរបស់មន្ត្រី ដូចខាងក្រោម៖

-អភិបាល អភិបាលខេត្ត-ក្រុង ស្រុក ខណ្ឌ ។

-អគ្គនាយក អគ្គនាយរងនគរបានជាតិ ។

-ប្រធាន អនុប្រធាននាយកដ្ឋាននគរបាលយុត្តិធម៌ ។

-ប្រធាន អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

-ស្នងការ ស្នងការរង ។

-ប្រធានការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល ។

-អធិការ អធិការរង

-ប្រធានប៉ុស្តិ៍ នគរបាលរដ្ឋបាល

ដោយឲ្យការរៀបចំសំណុំកុំរឿងបញ្ជូនទៅតុលាការ ជាសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ។

៣-អំពីនីតិវិធីនៃការរឹបអូសប្រាក់ក្នុងវង់ល្បែង និង វត្ថុតាង ៖

ក្នុងករណីណាក៏ដោយប្រាក់ដាក់ក្នុងវង់ល្បែង ប្រាក់មាននៅនឹងខ្លួនអ្នកចាត់ចែងល្បែងនៅនឹងខ្លួនមេល្បែង នៅនឹងខ្លួនភ្នាក់ងារល្បែង នៅនឹងខ្លួនអ្នកជួយស៊ីសងក្នុងវង់ល្បែង នៅនឹងខ្លួនអ្នកទទួលភារកិច្ចខាងគណនេយ្យ នៅនឹងខ្លួនអន្តរការី និងនៅនឹងខ្លួនអ្នកលេងល្បែង ត្រូវមន្ត្រីមានសមត្ថកិច្ច ដូចបានរៀបរាប់ខាងលើចាប់រឹបអូសហើយធ្វើកំណត់ហេតុអោយបានត្រឹមត្រូវបញ្ជូនទៅតុលាការ ។

ចំណែកវត្ថុតាងសម្រាប់បម្រើអោយការលេងល្បែងនោះក៏ត្រូវរឹបអូសដូចប្រាក់ដែរ ។

ការផលិត ការនាំចូលដើម្បីធ្វើអាជីវកម្ម ការលក់ឧបករណ៍ល្បែងស៊ីសងគ្រប់ប្រភេទដោយគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល ត្រូវផ្តន្ទាទោសតាមមាត្រា៨ នៃច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង ។ ឧបករណ៍នៃវត្ថុតាងនេះក៏មន្ត្រីមានសមត្ថកិច្ច ត្រូវរឹបអូសដែរ ។

ប្រាក់ និងវត្ថុតាងទាំងអស់ដែលរឹបអូសបានដូចខាងលើ មន្ត្រីមានសមត្ថកិច្ចត្រូវតែបញ្ជូនជាមួយនឹងសំណុំរឿងទៅតុលាការដើម្បីសម្រេចរឹបអូស ឬបំផ្លាញចោល ។

ចំពោះប្រាក់រង្វាន់សម្រាប់មន្ត្រីមានសមត្ថកិច្ច អង្គភាព និងជនដែលបានចូលរួមកិច្ចប្រតិបត្តិការនេះ និងមានកំណត់ដោយឡែកក្នុងអនុក្រឹត្យ ។

៤-អំពីប្រភេទនៃល្បែងស៊ីសងដែលត្រូវបង្ក្រាប ៖

-ល្បែងបៀគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់ ។

-ល្បែងឡូតូ ដែលស៊ីសងជាប្រាក់ ឬ វត្ថុតំណាងសាច់ប្រាក់ ។

-ឆ្នោតគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ រួមទាំងកន្ទុយលេខផង ។

-ឆ្នោតវត្ថុគ្រប់ប្រភេទ ។

-ល្បែងអាប៉ោង ធូ ឡុកឡាក់ យូគី និងខ្លាឃ្លោក ដែលស៊ីសងជាប្រាក់ ឬជាវត្ថុតំណាងជាសាច់ប្រាក់ ។

-ល្បែងជល់សត្វ ឬ ប្រណាំងសត្វគ្រប់ប្រភេទស៊ីសងជាប្រាក់ ឬជាវត្ថុតំណាងសាច់ប្រាក់ ។

-ល្បែងទឹកភ្លៀងគ្រប់រូបភាព ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់ ។

-ល្បែងរូលឡែត គ្រប់រូបភាពដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់

-ល្បែងវីដេអូហ្គេមគ្រប់ប្រភេទ ដែលស៊ីសងជាប្រាក់ ឬ ជាវត្ថុតំណាងសាច់ប្រាក់ ។

-ព្រមទាំងល្បែងស៊ីសងទាំងឡាយដទៃទៀត ។

ល្បែងស៊ីសងទាំងអស់ខាងលើនេះអាចលេងបាន បើមានការអនុញ្ញាតច្បាប់ពីរាជរដ្ឋាភិបាល ក្នុងករណីគ្មានការអនុញ្ញាតពីរាជរដ្ឋាភិបាល មន្ត្រីមានសមត្ថកិច្ចបល្បែងស៊ីសងដូចមានចែងក្នុងចំណុចទី២នៃសារាចរ នេះត្រូវចាត់វិធានការបង្ក្រាបជាបន្ទាន់។

ក្រសួងប្រគល់ភារកិច្ចអោយអគ្គនាយកដ្ឋាននគរបាលជាតិ ធ្វើជាសេនាធិការ ដើម្បីចង្អុលណែនាំលើកចិត្តនិងដឹកនាំអនុវត្តការងារនេះ ។

សារាចរនេះមានប្រសិទ្ធិភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ១៩៩៦

**សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង យូ ហុកគ្រី**

<u>កន្លែងទទួល</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-អគ្គធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទការល័យសម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី១
-ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រីទី២
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ក្រសួងយុត្តិធម៌
-ក្រសួងការពារជាតិ
-សេនាធិការនៃកងយោធពលខេមរភូមិន្ទ
-តុលាការខេត្ត-ក្រុង
-ក្រសួង ស្ថាប័ន
(ដើម្បីជូនជ្រាប)
-នាយកដ្ឋាននគរបាលជាតិ
-អភិបាលខេត្ត-ក្រុង
-អង្គភាពចំណុះក្រសួងមហាផ្ទៃ
(ដើម្បីអនុវត្ត)
-ឯកសារ-កាលប្បវត្តិ